# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ចាម

សាលក្រម

លេខៈ ៥០"ក" ចុះថ្ងៃទី១០

ខែមីនា ឆ្នាំ ២០២២

## តាមនាមប្រជារាស្ត្រខ្មែរ

## តុលាការខេត្តកំពង់ចាម

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃពុធ ១០កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥ ត្រូវនឹងថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ និងបន្តនៅថ្ងៃព្រហស្បតិ៍ ១រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥ ត្រូវនឹងថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២ លើសំណុំរឿងរដ្ឋប្បវេណីលេខៈ ២០៥ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២០ ៖

### ចៅក្រមទទួលបន្ទុក

ឯកឧត្តម [redacted] ជាប្រធានសាលាដំបូងខេត្តកំពង់ចាម

### ក្រឡាបញ្ជី

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ចាម

-សហដើមចោទ៖ ឈ្មោះ [redacted] រិត (រិទ្ធ) ភេទប្រុស អាយុ ៤៩ឆ្នាំ ជាតិខ្មែរ មុខរបរ គ្រូបង្រៀន និងប្រពន្ធឈ្មោះ [redacted] សុជានី ([redacted] ជានី) មានទីលំនៅ [redacted]។

-មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ៖ លោកស្រី [redacted]។

-ចុងចម្លើយ៖ ឈ្មោះ [redacted] សុភាព ភេទស្រី អាយុ ៤៤ឆ្នាំ ជាតិខ្មែរ មានទីលំនៅ [redacted]។

-មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ៖ លោក [redacted]។

<u>ដែលមានកម្មវត្ថុបណ្តឹងៈ</u>

១-បង្គាប់ឱ្យឈ្មោះ [redacted] សុភាព ផ្ទេរកម្មសិទ្ធិដើម្បីចុះបញ្ជីលើប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ លេខៈ ក.ច ០១៣៧១១ លេខ MvIII ០១៤៧/០០០២ ចុះថ្ងៃទី០៤.០៦.២០១៣ ស្ថិតនៅភូមិបុសខ្នុរ ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម ឱ្យមកឈ្មោះ [redacted] រិត (រិទ្ធ) និងប្រពន្ធឈ្មោះ [redacted] សុជានី ([redacted] ជានី) ដោយផ្អែកលើកិច្ចសន្យាលក់ផ្តាច់លេខៈ ៨៧/១៦ ចុះថ្ងៃទី២៤.០១.២០១៦។

២-បង្គាប់ឱ្យឈ្មោះ [redacted] សុភាព ផ្ទេរការកាន់កាប់សិទ្ធិលើអចលនវត្ថុលេខៈ ក.ច ០១៣៧១១ លេខ MvIII ០១៤៧/០០០២ ចុះថ្ងៃទី០៤.០៦.២០១៣ ស្ថិតនៅភូមិបុសខ្នុរ ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម



Scanned with CamScanner

ឱ្យមកឈ្មោះ [redacted] រិត (រិទ្ធ) និងប្រពន្ធឈ្មោះ [redacted] សុផានី ( [redacted] ផាន្នី) ដោយផ្អែកលើកិច្ចសន្យាលក់ផ្តាច់ លេខ: ៨៧/១៦ ចុះថ្ងៃទី២៤.០១.២០១៦។

៣-ឱ្យចុងចម្លើយ ជាអ្នកទទួលបន្ទុក បង់ប្រាក់ប្រដាប់ក្តី និងពន្ធផ្សេងៗ ក្នុងរឿងក្តី។

៤-ឱ្យចុងចម្លើយ សងការខូចខាតពេលវេលា និងសោហ៊ុយលើការចំណាយផ្សេងៗ របស់សហដើមចោទឈ្មោះ [redacted] រិត (រិទ្ធ) និងប្រពន្ធឈ្មោះ [redacted] សុផានី ( [redacted] ផាន្នី) ចំនួន ៥០.០០០.០០០ "ហាសិបលាន"រៀល។

**ក-ខ្លឹមសារសាលក្រមដែលទាមទារដោយភាគី៖**

**-សាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ**

១-បង្គាប់ឱ្យឈ្មោះ [redacted] សុភាព ផ្ទេរកម្មសិទ្ធិដើម្បីចុះបញ្ជីលើប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ លេខ: ក.ច ០១៣៧១១ លេខ MVIII ០១៤៧/០០០២ ចុះថ្ងៃទី០៤.០៦.២០១៣ ស្ថិតនៅភូមិបុសខ្នុរ ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម ឱ្យមកឈ្មោះ [redacted] រិត (រិទ្ធ) និងប្រពន្ធឈ្មោះ [redacted] សុផានី [redacted] ផាន្នី) ដោយផ្អែកលើកិច្ចសន្យាលក់ផ្តាច់លេខ: ៨៧/១៦ ចុះថ្ងៃទី២៤.០១.២០១៦។

២-បង្គាប់ឱ្យឈ្មោះ [redacted] សុភាព ផ្ទេរការកាន់កាប់សិទ្ធិលើអចលនវត្ថុលេខ: ក.ច ០១៣៧១១ លេខ MVIII ០១៤៧/០០០២ ចុះថ្ងៃទី០៤.០៦.២០១៣ ស្ថិតនៅភូមិបុសខ្នុរ ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម ឱ្យមកឈ្មោះ [redacted] រិត (រិទ្ធ) និងប្រពន្ធឈ្មោះ [redacted] សុផានី ( [redacted] ផាន្នី) ដោយផ្អែកលើកិច្ចសន្យាលក់ផ្តាច់ លេខ: ៨៧/១៦ ចុះថ្ងៃទី២៤.០១.២០១៦។

៣-ឱ្យចុងចម្លើយ ជាអ្នកទទួលបន្ទុក បង់ប្រាក់ប្រដាប់ក្តី និងពន្ធផ្សេងៗ ក្នុងរឿងក្តី។

៤-ឱ្យចុងចម្លើយ សងការខូចខាតពេលវេលា និងសោហ៊ុយលើការចំណាយផ្សេងៗ របស់សហដើមចោទឈ្មោះ [redacted] រិត (រិទ្ធ) និងប្រពន្ធឈ្មោះ [redacted] សុផានី (យ៉ែម ផាន្នី) ចំនួន ៥០.០០០.០០០ "ហាសិបលាន" រៀល។

**ខ-អង្គហេតុ និងចំណុចវិវាទ**

**១-អង្គហេតុជាមូលហេតុនៃការទាមទារ**

១.១-សហដើមចោទ បានទិញដីចំនួន០២កន្លែងពីចុងចម្លើយ

ទី១-ដីចំការកៅស៊ូនៅខេត្តរតនគិរី ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ: រ.គ ០០៣៦៣៧ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២ ក្នុងតម្លៃ ១៣០,០០០$ (មួយសែនបីម៉ឺន)ដុល្លារអាមេរិក

ទី២-ដីលំនៅដ្ឋាននៅស្រុកចំការលើ ខេត្តកំពង់ចាម ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ: ក.ច ០១៣៧១១ លេខ MVIII ០១៤៧/០០០២ ចុះថ្ងៃទី០៤.០៦.២០១៣ក្នុងតម្លៃ ៣០,០០០$ (បីម៉ឺន)ដុល្លាររអាមេរិក។

សរុប ១៦០,០០០$ (មួយសែនប្រាំមួយម៉ឺន)ដុល្លាររអាមេរិក។

ដីទាំងពីរកន្លែងខាងលើសុទ្ធតែជាប់ប្លង់នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ដោយហេតុថា ចុងចម្លើយជំពាក់បំណុលដើមចោទមួយចំនួនពុំមានប្រាក់សងហើយសុំដើមចោទទិញផ្តាច់ដីទាំងពីរកន្លែងនេះ បើពុំនោះទេនឹងត្រូវគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់រឹបអូស។ ដោយយល់ថាជាបងប្អូន ដើមចោទយល់

ព្រមតាមសំណើ និងបានសម្រេចជាកិច្ចសន្យាលក់ផ្ដាច់រវាងដើមចោទ និងចុងចម្លើយលេខ ៨៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៦ លើអចលនវត្ថុដីទំហំ ១១x៣៧ ម៉ ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ច ០១៣៧១១ លេខ MVIII ០១៤៧/០០០២ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៣ ស្ថិតនៅភូមិបុសខ្នុរ ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម ក្នុងតម្លៃ ៣០,០០០$ (បីម៉ឺន)ដុល្លារអាមេរិក រីឯដីចំការកៅស៊ូនៅខេត្តរតនគិរីបានដោះស្រាយចប់ហើយ។

សហដើមចោទបានបង់ប្រាក់នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ជាបន្តបន្ទាប់ និងបង់ផ្ដាច់តាមរយៈឈ្មោះ សេង សារឿន ដែលជាកូនបំណុលរួមជាមួយចុងចម្លើយ ព្រមទាំងបានសងបំណុលគេជំនួសឱ្យចុងចម្លើយ និងបូករួមទាំងបំណុលផងដូចខាងក្រោមៈ

១-បំណុលដើមខ្ចីដើមចោទ ០២លើកមានប្រាក់ចំនួន ៥៦,៥០០$ និងការប្រាក់ =២៣,៧៣០$ (ពីរម៉ឺនបីពាន់ប្រាំពីររយសាមសិប)ដុល្លារអាមេរិក។

២-បង់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ជំនួសក្បាល ៦០,០០០$ = ៤២,៤២៨$ (បួនម៉ឺនពីរពាន់បួនរយម្ភៃប្រាំបី)ដុល្លារអាមេរិក។

៣-បង់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ជំនួសក្បាល ២០,០០០$ = ២៥,០០៥$ (ពីរម៉ឺនប្រាំពាន់សូន្យរយសូន្យប្រាំ)ដុល្លារអាមេរិក។

៤-សងបំណុលគេជំនួស = ២១,៣៥៥$ (ពីរម៉ឺនមួយពាន់បីរយហាសិបប្រាំ)ដុល្លារអាមេរិក

សរុបទាំង០៤លើកខាងលើស្មើនឹងប្រាក់ចំនួន ១៦៩,០១៨$ (មួយសែនប្រាំមួយម៉ឺនប្រាំបួនពាន់សូន្យរយដប់ប្រាំបី)ដុល្លារអាមេរិក លើសតម្លៃដីទាំងពីរកន្លែងដែលស្មើនឹងប្រាក់ចំនួន ១៦០,០០០$ (មួយសែនប្រាំមួយម៉ឺន)ដុល្លារអាមេរិក ប៉ុន្តែដើមចោទសុខចិត្តកាត់ត្រឹមតម្លៃដីប៉ុណ្ណោះ។ ដោយពេលបង់ផ្ដាច់គ្រប់ចំនួនហើយចុងចម្លើយបានដកប្លង់ដីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់តាមរយៈឈ្មោះ [redacted] វីរៈ ត្រូវជាបងប្អូនបង្កើតរបស់ចុងចម្លើយបានយកមកប្រគល់ឱ្យដើមចោទហើយក្រោយមកដើមចោទបានយកប្លង់ដីនោះទៅកាត់ឈ្មោះផ្ទេរកម្មសិទ្ធិស្រាប់តែចុងចម្លើយគេចវេសពុំព្រមទៅផ្ដិតមេដៃផ្ទេរប្លង់ដីឱ្យទេ និងបានប្ដឹងសុំរំលាយកិច្ចសន្យាទិញ-លក់ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៦ នោះចោលទៀត។ ដើមចោទក៏បានប្ដឹងចុងចម្លើយពីបទរំលោភលើទំនុកចិត្តមកសាលាដំបូងខេត្តកំពង់ចាម ហើយត្រូវបានតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់រយៈពេល២ឆ្នាំ និងបានចេញដីកាបង្គាប់ឱ្យចាប់ខ្លួនចុងចម្លើយ ហើយចុងចម្លើយបានរត់គេចខ្លួនរហូតដល់សព្វថ្ងៃ។ ដីទំនាស់នេះដើមចោទទិញមានរយៈពេល៥ឆ្នាំ ១០ខែ ហើយ ចុងចម្លើយពុំបានប្ដឹងទាមទារអ្វីទេ ទើបតែពេលថ្មីៗនេះក៏បានប្ដឹងតវ៉ា។

១.២-ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ច ០១៣៧១១ លេខ MVIII ០១៤៧/០០០២ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៣ របស់ចុងចម្លើយនៅលើដៃដើមចោទ តែដីទំនាស់នោះចុងចម្លើយឱ្យប្អូនស្នាក់នៅពុំទាន់បានប្រគល់ឱ្យដើមចោទកាន់កាប់នៅឡើយទេ។

១.៣-ចុងចម្លើយជាអ្នកមានកំហុសត្រូវទទួលរ៉ាប់រងប្រាក់ប្រដាប់ក្ដី និងពន្ធផ្សេងៗ។

១.៤-ចុងចម្លើយបានធ្វើឱ្យដើមចោទខាតបង់ពេលវេលា និងសោហ៊ុយលើការចំណាយផ្សេងៗក្នុងរឿងក្ដីច្រើនណាស់ បណ្ដាលមកពីកំហុសចុងចម្លើយ។

២-ការទទួលស្គាល់ឬ មិនទទួលស្គាល់ការទាមទារ

-ទទួលស្គាល់ប្រាក់ជំពាក់ដើមចោទចំនួន ៥៦,៥០០$ (ប្រាំម៉ឺនប្រាំមួយពាន់ប្រាំរយ)ដុល្លារអាមេរិក។

-ទទួលស្គាល់ប្រាក់សងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ជំនួស(បង់ផ្តាច់)ចំនួន ២៩,៥៤២$ (ពីរម៉ឺនប្រាំបួនពាន់ប្រាំរយសែសិបពីរ)ដុល្លារអាមេរិក ក្រៅពីនោះច្រានចោលទាំងអស់។

៣-ការតវ៉ា

៣.១-ចុងចម្លើយពិតជាបានលក់ដីចំនួន០២កន្លែងឱ្យដើមចោទប្រាកដមែនគឺដី០១កន្លែង ស្ថិតនៅខេត្តរតនគិរីជាប្រភេទដីចំការ និងដីទី០២ ស្ថិតនៅក្នុងស្រុកចំការលើ ខេត្តកំពង់ចាម ជាប្រភេទដីសង់លំនៅដ្ឋាន ក្នុងតម្លៃ ១៦០,០០០$ (មួយសែនប្រាំមួយម៉ឺន)ដុល្លារអាមេរិក ក្នុងនោះដើមចោទកាត់កងឱ្យចុងចម្លើយទទួលស្គាល់លើប្រាក់កម្ចីចំនួន ៥៦,៥០០$ (ប្រាំម៉ឺនប្រាំមួយពាន់ប្រាំរយ)ដុល្លារអាមេរិក បង់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ផ្តាច់ជំនួសពីរលើកស្មើនឹង ២៩,៥៤២$ (ពីរម៉ឺនប្រាំបួនពាន់ប្រាំរយសែសិបពីរ)ដុល្លារអាមេរិក សរុបស្មើចំនួន ៨៦,០៤២$ (ប្រាំបីម៉ឺនប្រាំមួយពាន់សូន្យរយសែសិបពីរ)ដុល្លារអាមេរិក ទូទាត់ទៅដើមចោទនៅខ្វះប្រាក់ចុងចម្លើយចំនួន ៧៣,៩៥៨$ (ប្រាំពីរម៉ឺនបីពាន់ប្រាំបួនរយហាសិបប្រាំបី)ដុល្លារអាមេរិកទៀតមិនទាន់ទូទាត់ ហេតុដូច្នេះហើយទើបចុងចម្លើយពុំព្រមផ្តិតមេដៃផ្ទេរកម្មសិទ្ធិជូនដើមចោទ។ ដោយឡែកដើមចោទអះអាងថាបានសងប្រាក់ជំនួសចុងចម្លើយដែលជំពាក់គេនោះចុងចម្លើយមិនទទួលស្គាល់ទេព្រោះគ្មានឯកសារ។ ប្រាក់បង់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ដាក់ឈ្មោះ [redacted] សារឿន មិនទទួលស្គាល់ទេពីព្រោះឈ្មោះ [redacted] សារឿន ជាកូនបំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ត្រូវមានកាតព្វកិច្ចបង់ឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ត្រង់ថាឈ្មោះ [redacted] សារឿន បានប្រាក់មកពីណាជារឿងរបស់ឈ្មោះ [redacted] សារឿន។ ការបង់ផ្តាច់ឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់លើកចុងក្រោយចំនួន ២៣,៩៥៨$ (ពីរម៉ឺនបីពាន់ប្រាំបួនរយហាសិបប្រាំបី)ដុល្លារអាមេរិកនោះមិនទទួលស្គាល់ទេ ព្រោះឈ្មោះអ្នកបង់ផ្តាច់គឺ [redacted] សារឿន ដែលជាកូនបំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់។ បើដើមចោទយល់ព្រមទូទាត់ប្រាក់ដែលនៅខ្វះចំនួន ៧៣,៩៥៨$ (ប្រាំពីរម៉ឺនបីពាន់ប្រាំបួនរយហាសិបប្រាំបី)ដុល្លារអាមេរិក តាមការទាមទារ ចុងចម្លើយនិងផ្តិតមេដៃផ្ទេរកម្មសិទ្ធិដីជូនភ្លាម។

៣.២-ចុងចម្លើយពិតជាឯកភាពឱ្យឈ្មោះ [redacted] សារឿន យកប្រាក់ពីដើមចោទទៅលួសប្លង់ដីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ដើម្បីលក់ឱ្យដើមចោទមែន ហើយប្លង់ដីនោះបានប្រគល់ឱ្យដើមចោទតាមរយៈឈ្មោះ [redacted] វីរៈ តែដើមចោទទេមិនព្រមទូទាត់ប្រាក់ដែលនៅខ្វះទើបចុងចម្លើយពុំព្រមផ្តិតមេដៃផ្ទេរកម្មសិទ្ធិដីឱ្យ។

៣.៣-ប្រាក់ប្រដាប់ក្តី និងពន្ធផ្សេងទៀតដើមចោទជាអ្នកមានកំហុសត្រូវទទួលរ៉ាប់រងខ្លួនឯង។

៣.៤-សំណងការខាតបង់ពេលវេលា និងសោហ៊ុយក្នុងការចំណាយផ្សេងៗ ចុងចម្លើយមិនទទួលស្គាល់ទេ។

៤-ការទទួលស្គាល់ ឬមិនទទួលស្គាល់ការតវ៉ា

៤.១-ការតវ៉ារបស់ចុងចម្លើយចំនុចទី១ ខាងលើមិនទទួលយកទេ ដោយហេតុថាដីនៅខេត្តរតនគិរីបានដោះស្រាយបញ្ចប់រួចហើយ បច្ចុប្បន្ននៅតែដី និងផ្ទះនៅស្រុកចំការលើ ខេត្តកំពង់ចាម តែប៉ុណ្ណោះ



Scanned with CamScanner

ហើយដីនេះបានបង់ប្រាក់ផ្តាច់រួចរាល់ហើយ ប្លង់ដីក៏ចុងចម្លើយបានប្រគល់ឱ្យដើមចោទរួចហើយដែរ នៅតែចុងចម្លើយទៅផ្តិតមេដៃដើម្បីបំពេញនីតិវិធីផ្ទេរកម្មសិទ្ធិឱ្យដើមចោទតែប៉ុណ្ណោះ។

៤.២-ការតវ៉ាចំនុចទី២, ៣, ៤ ពុំទទួលស្គាល់ដែរ។

គ-ចំណុចវិវាទ

១-ដើមចោទពិតជានៅខ្វះសាច់ប្រាក់ចំនួន ៧៣,៩៥៨$ (ប្រាំពីរម៉ឺនបីពាន់ប្រាំបួនរយហាសិបប្រាំបី) ដុល្លារអាមេរិក ថ្លៃទិញដីពីចុងចម្លើយដូចការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយមែន ឬយ៉ាងណា?

២-ប្រាក់ចំនួន ៥០,០០០,០០០៛ (ហាសិបលាន)រៀលដែលដើមចោទទាមទារឱ្យចុងចម្លើយសងការខូចខាតពេលវេលា និងសេវាកម្មផ្លូវច្បាប់ផ្សេងៗនោះត្រឹមត្រូវដែរ ឬទេ?

## សំអាងហេតុ

១-នៅក្នុងរឿងក្តីនេះដើមចោទ និងចុងចម្លើយបានទទួលស្គាល់ថាពិតជាមានអង្គហេតុនៃការលក់-ទិញដីចំនួន០២កន្លែងប្រាកដមែន ០១កន្លែងជាដីចំការនៅខេត្តរតនគិរី និង០១កន្លែងទៀតជាដី និងផ្ទះនៅស្រុកចំការលើ ខេត្តកំពង់ចាម ក្នុងតម្លៃសរុបចំនួន ១៦០,០០០$ (មួយសែនប្រាំមួយម៉ឺន)ដុល្លារអាមេរិក។ ចុងចម្លើយបានបដិសេធនូវអង្គហេតុប្រគល់ប្រាក់ដោយលើកឡើងថា ដើមចោទបានទូទាត់ប្រាក់ថ្លៃដីនោះបានត្រឹមតែ ៨៦,០៤២$ (ប្រាំបីម៉ឺនប្រាំមួយពាន់សូន្យរយសែសិបពីរ)ដុល្លារអាមេរិកតែប៉ុណ្ណោះ នៅខ្វះ ៧៣,៩៥៨$ (ប្រាំពីរម៉ឺនបីពាន់ប្រាំបួនរយហាសិបប្រាំបី)ដុល្លារអាមេរិក ទៀតពុំទាន់បានទូទាត់នៅឡើយ ទើបខ្លួនពុំព្រមផ្តិតមេដៃផ្ទេរប្លង់កម្មសិទ្ធិដីឱ្យ។

២-មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយបានលើកឡើងថាបើដើមចោទព្រមបង់ប្រាក់ដែលនៅខ្វះចំនួន ៧៣,៩៥៨$ (ប្រាំពីរម៉ឺនបីពាន់ប្រាំបួនរយហាសិបប្រាំបី)ដុល្លារអាមេរិក តាមការទាមទារ ចុងចម្លើយនឹងយល់ព្រមផ្តិតមេដៃផ្ទេរកម្មសិទ្ធិដីឱ្យភ្លាម។

៣-មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានអះអាងថា ប្រាក់ថ្លៃទិញដីទាំងពីរកន្លែងពីចុងចម្លើយនោះ ដើមចោទបានទូទាត់គ្រប់ចំនួនអស់ហើយមិនមាននៅខ្វះទៀតទេ។

៤-មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានលើកឡើងថា ចុងចម្លើយបានជំពាក់បំណុលដើមចោទគ្មានប្រាក់សងទើបសុំឱ្យដើមចោទទិញផ្តាច់ដី០២កន្លែង នៅខេត្តរតនគិរី ដីចំការ ០១កន្លែងតម្លៃ ១៣០,០០០$ (មួយសែនបីម៉ឺន)ដុល្លារអាមេរិក ដីនិងផ្ទះនៅស្រុកចំការលើ ខេត្តកំពង់ចាម ០១កន្លែងតម្លៃ ៣០,០០០$ (បីម៉ឺន)ដុល្លារអាមេរិក សរុបស្មើនឹង ១៦០,០០០$ (មួយសែនប្រាំមួយម៉ឺន)ដុល្លារអាមេរិក បើពុំនោះទេ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់នឹងរឹបអូសលក់ឡាយឡុងហើយ។ ដោយយល់ថាចុងចម្លើយជាបងប្អូនដើមចោទក៏យល់ព្រមទិញដីទាំងពីរកន្លែងនោះ តាមរយៈបង់រំលោះ និងបង់ផ្តាច់នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ព្រមទាំងប្រាក់បំណុលផងឃើញថាមានចំនួនលើសតម្លៃទិញដីនោះផង។ ពេលបង់ផ្តាច់ឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ រួចចុងចម្លើយបានឱ្យប្អូនយកប្លង់ដីមកប្រគល់ឱ្យដើមចោទទៀតផង តែពេលកាត់ឈ្មោះស្រាប់តែចុងចម្លើយពុំព្រមសហការផ្តិតមេដៃឱ្យទេ ទើបកើតជារឿងប្តឹងទាមទារដូចក្នុងសំណុំរឿងក្តីនេះ។

រីឯដីចំការនៅខេត្តរតនគិរី បានដោះស្រាយចប់រួចរាល់ហើយនៅតែដី និងផ្ទះនៅចំការលើ ខេត្តកំពង់ចាម តែប៉ុណ្ណោះ។

ការអះអាងរបស់ដើមចោទ និងមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបញ្ជាក់ដោយភស្តុតាងដូចខាងក្រោម៖

១-កិច្ចសន្យាទិញ-លក់ដីរវាងដើមចោទ និងចុងចម្លើយចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៦។

២-ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ច ០១៣៧១១ លេខ Mvııı ០១៤៧/០០០២ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៣។

៣-កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៥ និងកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៥ ប្រាក់ចំនួន ៥៦,៥០០$ (ប្រាំមុឺនប្រាំមួយពាន់ប្រាំរយ)ដុល្លារអាមេរិក។

៤-ការប្រាក់ស្មើ ២៣,៧៣០$ (ពីរមុឺនបីពាន់ប្រាំពីររយសាមសិប)ដុល្លារអាមេរិក។

៥-សងបំណុលជួសទៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ក្បាល ៦០,០០០$ = ៤២,៤២៨$ (បួនមុឺនពីរពាន់បួនរយម្ភៃប្រាំបី)ដុល្លារអាមេរិក។

៦-សងបំណុលជួសទៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ក្បាល ២០,០០០$ = ២៥,០០៥$ (ពីរមុឺនប្រាំពាន់សូន្យរយសូន្យប្រាំ)ដុល្លារអាមេរិក។

៧-សងបំណុលជំនួសឱ្យចុងចម្លើយក្រៅពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ = ២១,៣៥៥$ (ពីរមុឺនមួយពាន់បីរយហាសិបប្រាំ)ដុល្លារអាមេរិក។

៨-ប័ណ្ណដាក់ប្រាក់បញ្ញើ (បង្កាន់ដៃបង់ប្រាក់) នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ចំនួន ២២សន្លឹក។

៩-វិក័យប័ត្របង់ផ្តាច់ជូនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៦ ស្មើ ១៥,២០២$ (មួយមុឺនប្រាំពាន់ពីររយសូន្យពីរ)ដុល្លារអាមេរិក និងចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ស្មើ ១៤,៣៤២$ (មួយមុឺនបួនពាន់បីរយសែសិបពីរ)ដុល្លារអាមេរិក។

១០-សាលក្រមព្រហ្មទណ្ឌលេខ ៦២៧(យ) ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ចាម។

៥-មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានអះអាងថាចុងចម្លើយបានប្រគល់ដី និងប្លង់ដីជូនដើមចោទមានរយៈពេល៥ឆ្នាំ ១០ខែ ហើយទើបមកប្តឹងសុំរំលាយកិច្ចសន្យា សួរថាបើចុងចម្លើយមិនព្រមហេតុអ្វីក៏មិនព្រមប្តឹងរយៈពេលយូរហើយ ម្យ៉ាងទៀតតាមបញ្ញត្តិមាត្រា៤៨២ នៃក្រមរដ្ឋប្បវេណីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលគឺចុងចម្លើយពុំមានសិទ្ធិទាមទារប្រាក់ថ្លៃទិញដី និងផ្ទះនេះទៀតទេ។

៦-តាមការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយបញ្ជាក់ថា កូនក្តីខ្លួនពិតជាបានលក់ដីផ្តាច់ឱ្យដើមចោទដូចការអះអាងរបស់ដើមចោទមែន ប៉ុន្តែដើមចោទនៅពុំទាន់ប្រគល់ប្រាក់ឱ្យមកកូនក្តីខ្លួនគ្រប់ចំនួននៅឡើយទេគឺប្រគល់តាមការទូទាត់ប្រាក់ជំពាក់ និងបង់ប្រាក់ជូនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ បានចំនួនតែ ៨៦,០៤២$ (ប្រាំបីមុឺនប្រាំមួយពាន់សូន្យរយសែសិបពីរ)ដុល្លារអាមេរិក តែប៉ុណ្ណោះនៅខ្វះចំនួន ៧៣,៩៥៨$ (ប្រាំពីរមុឺនបីពាន់ប្រាំបួនរយហាសិបប្រាំបី)ដុល្លារអាមេរិក ទៀតពុំទាន់ទូទាត់នៅ



Scanned with CamScanner

ឡើយទេ។ ក្នុងសាច់ប្រាក់ថ្លៃដីចំនួន ១៦០,០០០$ (មួយសែនប្រាំមួយម៉ឺន)ដុល្លារអាមេរិក នោះកូនក្តីខ្លួនទទួលស្គាល់ការទូទាត់ប្រាក់ជំពាក់ចំនួន ៥៦,៥០០$ (ប្រាំម៉ឺនប្រាំមួយពាន់ប្រាំរយ)ដុល្លារអាមេរិក សងជំនួសនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ (បង់ផ្តាច់) ចំនួន ២៩,៥៤២$ (ពីរម៉ឺនប្រាំបួនពាន់ប្រាំរយសែសិបពីរ) ដុល្លារអាមេរិក សរុបចំនួន ៨៦,០៤២$ (ប្រាំបីម៉ឺនប្រាំមួយពាន់សូន្យរយសែសិបពីរ)ដុល្លារអាមេរិក ការទូទាត់ផ្សេងទៀតក្រៅពីនេះកូនក្តីខ្លួនពុំទទួលស្គាល់ទេ។ ដូច្នេះដើមចោទត្រូវប្រគល់ប្រាក់ចំនួន ៧៣,៩៥៨$ (ប្រាំពីរម៉ឺនបីពាន់ប្រាំបួនរយហាសិបប្រាំបី)ដុល្លារអាមេរិក ដែលជាប្រាក់នៅខ្វះថ្លៃទិញដីខាងលើមកឱ្យកូនក្តីខ្លួនជាចុងចម្លើយតាមការទាមទារនោះកូនក្តីខ្លួននឹងផ្តិតមេដៃផ្ទេរកម្មសិទ្ធិដីជូនដើមចោទភ្លាម។

៧-ការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយពុំមានភស្តុតាងសំអាងច្បាស់លាស់ពីការទាមទាររបស់ខ្លួនឡើយ។

៨-ភាគីចុងចម្លើយពុំបានដាក់បណ្តឹងតបដើម្បីឱ្យតុលាការសម្រេចតាមការទាមទារទេ។

៩-តាមសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយបានបញ្ជាក់អំពីអង្គហេតុនៃការលក់ដីផ្តាច់ឱ្យដើមចោទដោយមានកិច្ចសន្យាចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៦, អង្គហេតុនៃការខ្ចីប្រាក់ពីដើមចោទចំនួន ០២លើកដោយមានកិច្ចសន្យាចងការប្រាក់ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៥ និងកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៥, អង្គហេតុនៃការខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់រួមគ្នាជាមួយឈ្មោះ[redacted]វីរៈ ជាបងប្រុស និងឈ្មោះ [redacted]សារឿន ត្រូវជាប្អូនស្រីបង្កើតរបស់ដើមចោទដោយមានកិច្ចសន្យាខ្ចីប្រាក់ក្បាលទី១ ទំហំសាច់ប្រាក់ចំនួន ៦០,០០០$ (ប្រាំមួយម៉ឺន)ដុល្លារអាមេរិក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣, ប្រាក់ក្បាលទី២ ទំហំសាច់ប្រាក់ ២០,០០០$ (ពីរម៉ឺន)ដុល្លារអាមេរិក ចុះថ្ងៃទី១៨ ខែមិនា ឆ្នាំ២០១៥ អង្គហេតុនៃការកាត់កងប្រាក់ជំពាក់ដើមចោទ និងការបង់ផ្តាច់ជូនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ស៊ីសង្វាក់ និងអង្គហេតុដែលលើកឡើងរបស់ដើមចោទ និងមេធាវីតំណាងដោយអាណត្តិរបស់ដើមចោទដែលបង្ហាញថាមានការពាក់ព័ន្ធចំពោះការទាមទាររបស់ដើមចោទក្នុងរឿងក្តីនេះដោយភ្ជាប់មកជាមួយឯកសារភស្តុតាងគ្រប់គ្រាន់ច្បាស់លាស់ក្នុងការទាមទារ។

១០-តាមចម្លើយសាក្សីឈ្មោះ[redacted]ចំរើន ធ្វើការនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់បានបញ្ជាក់ក្នុងសំណុំរឿងព្រហ្មទណ្ឌនាពេលសវនាការថា ប្រាក់កម្ចីនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់នោះគឺឈរឈ្មោះដោយឈ្មោះ [redacted] សារឿន,[redacted]វីរៈ និងឈ្មោះ [redacted]សុភាព រួមគ្នាដោយមានឈ្មោះ[redacted] សុផល ជាអ្នកធានា គឺខ្ចីដាក់ហ៊ីប៉ូតែកទឹកប្រាក់ ៦០,០០០$ (ប្រាំមួយម៉ឺន)ដុល្លារអាមេរិក និង ២០,០០០$ (ពីរម៉ឺន)ដុល្លារអាមេរិក បន្ថែម។ ឈ្មោះ [redacted] សារឿន ជាអ្នកបង់ប្រាក់ប្រចាំខែ ក្រោយកម្ចីទាំងពីរលើកខាងលើមានឈ្មោះ [redacted] រិទ្ធ ជាអ្នកបង់បន្តរហូតដល់ដាច់កម្ចីទាំងពីរ និងបានប្រគល់ប្លង់ដីឱ្យឈ្មោះ [redacted] រិទ្ធ។

១១-តាមភស្តុតាងជាឯកសារដែលដើមចោទស្នើសុំឱ្យតុលាការពិនិត្យរួមមានៈ

-កិច្ចសន្យាលក់ដីផ្តាច់រវាងដើមចោទ និងចុងចម្លើយ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៦។

-ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ច ០១៣៧១១ លេខ MvIII ០១៤៧/០០០២ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៣។



Scanned with CamScanner

-កិច្ចសន្យាខ្ចីប្រាក់សរុប ៥៦,៥០០$ (ប្រាំម៉ឺនប្រាំមួយពាន់ប្រាំរយ) ដុល្លារអាមេរិក ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៥ និងចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៥។

-ប័ណ្ណដាក់ប្រាក់បញ្ញើ (បង្កាន់ដៃបង់ប្រាក់) នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ចំនួន ២២ សន្លឹក។

-កិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី១៨ ខែមិនា ឆ្នាំ២០១៥។

-កាលវិភាគសងប្រាក់ចំនួន០១ច្បាប់ ចុះថ្ងៃទី២៧ ខែមិនា ឆ្នាំ២០១៥។

-ប័ណ្ណដាក់ប្រាក់បញ្ញើចំនួន០១សន្លឹកសងផ្តាច់ទៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ដែលមានសាច់ប្រាក់ចំនួន ១៥,២០៥$ (មួយម៉ឺនប្រាំពាន់ពីររយសូន្យប្រាំ)ដុល្លារអាមេរិក ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ ២០១៦ ។

-កិច្ចសន្យាខ្ចីចងការប្រាក់ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣។

-កាលវិភាគសងប្រាក់០១សន្លឹក ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៣។

-ប័ណ្ណដាក់ប្រាក់បញ្ញើ (បង្កាន់ដៃបង់ប្រាក់) សងផ្តាច់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ចំនួន ០១សន្លឹក មានសាច់ប្រាក់ចំនួន ១៤,៣៤២$ (មួយម៉ឺនបួនពាន់បីរយសែសិបពីរ)ដុល្លារអាមេរិក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧។ ក្រោយពេលតុលាការពិនិត្យលើភស្តុតាងខាងលើទាំងអស់នេះហើយឃើញថាពិតជាមានសារៈប្រយោជន៍ជាមូលដ្ឋានក្នុងការទាមទារ តុលាការទទួលពិចារណា។

១២-ការទាមទាររបស់ភាគីដើមចោទដោយផ្អែកលើអង្គហេតុ អង្គច្បាប់ ភស្តុតាង សាក្សី ដូចបានបង្ហាញខាងលើឃើញថាមានហេតុផលសមរម្យ គប្បីតុលាការសម្រេចតាមការទាមទារ។

១៣-ការអះអាងបញ្ជាក់របស់ភាគីចុងចម្លើយពុំមានហេតុផលសមរម្យតាមច្បាប់ទេ គប្បីតុលាការប្រានចោលការទាមទារក្នុងរឿងក្តីនេះ។

១៤-ការទាមទារសំណងការខូចខាតពេលវេលា និងសោហ៊ុយសេវាកម្មផ្នែកច្បាប់ចំនួន ៥០,០០០,០០០៛ (ហាសិបលាន)រៀល របស់ភាគីដើមចោទ តុលាការយល់ឃើញថាមានចំនួនច្រើនលើសលុបមិនសមហេតុផលនេះ គប្បីតុលាការប្រានចោលមួយផ្នែក។

១៥-ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុនៃដី និងផ្ទះទំនាស់លេខ ក.ច ០១៣៧១១ លេខ MVIII ០១៤៧/០០០២ ចុះថ្ងៃទី០៤.០៦.២០១៣ ស្ថិតនៅក្នុងដៃរបស់ភាគីដើមចោទដែលជាអ្នកប្តឹងទាមទារ ទោះបីចុងចម្លើយពុំព្រមចូលមកសហការក្នុងការផ្តល់ស្នាមមេដៃដើម្បីបំពេញនីតិវិធីក្នុងការផ្ទេរកម្មសិទ្ធិក៏ដោយក៏មន្ទីរដែលមានសមត្ថកិច្ចអាចបំពេញបែបបទតាមនីតិវិធីដែលអវត្តមានភាគីចុងចម្លើយក្នុងការផ្ទេរម្ចាស់កម្មសិទ្ធិករនេះតាមច្បាប់បានដែរ។

១៦-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចុងចម្លើយ។

## <u>សេចក្តីសម្រេចបញ្ជប់</u>

១-បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] សុភាព ប្រគល់ដីដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខៈ ក.ច ០១៣៧១១ លេខ MVIII ០១៤៧/០០០២ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៣ ស្ថិតនៅភូមិបុសខ្នុរ ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម ឱ្យមកឈ្មោះ [redacted]វិត (វិទ្ធ) និងប្រពន្ធឈ្មោះ [redacted]សុជានី ([redacted]ជានី)។

២-បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] សុភាព ផ្ទេរកម្មសិទ្ធិដីដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ: ក.ច ០១៣៧១១ លេខ MVIII ០១៤៧/០០០២ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៣ ស្ថិតនៅភូមិបុសខ្នុរ ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម ឱ្យមកឈ្មោះ [redacted] រិត (រិទ្ធ) និងប្រពន្ធឈ្មោះ [redacted] សុផានី ([redacted] ផានី្ម) ដើម្បីចុះបញ្ជី។

៣-បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] សុភាព សងសំណងការអន្តរាយ និងសោហ៊ុយចំណាយផ្សេងៗ ចំនួន ១០,០០០,០០០ (ដប់លាន)រៀល ឱ្យទៅដើមចោទឈ្មោះ [redacted] រិត (រិទ្ធ) និងប្រពន្ធឈ្មោះ [redacted] សុផានី ([redacted] ផានី្ម)។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

**ចៅក្រម**

ហត្ថលេខា និងត្រា: [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ១៤រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

កំពង់ចាម, ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

បានឃើញ

**ចៅក្រម**

[redacted]